

៩

# សិទ្ធិទទួលបានការការពារក្តីដោយខ្លួនឯង ឬសិទ្ធិមានមេធាវី

## និយមន័យ

ជនជាប់ចោទនៃបទព្រហ្មទណ្ឌទាំងអស់មានសិទ្ធិការពារក្តីរបស់ខ្លួនដោយផ្ទាល់ ឬការពារក្តីតាមរយៈមេធាវីដែលខ្លួនបានជ្រើសរើស។

សិទ្ធិការការពារក្តីដោយខ្លួនឯងចំពោះបុគ្គល ដែលជាប់ចោទពីបទព្រហ្មទណ្ឌ បានធានាថាមានសិទ្ធិ ដោយសិទ្ធិនេះមានន័យថា ជនជាប់ចោទអាចមានសិទ្ធិក្នុងការបដិសេធជំនួយពីមេធាវីនៅក្នុងបរិបទជាក់លាក់ណាមួយ។

ដើម្បីឱ្យសិទ្ធិការពារក្តីដោយខ្លួនឯង ឬសិទ្ធិមានមេធាវីមានប្រសិទ្ធិភាព បុគ្គលដែលត្រូវជាប់ចោទពីបទព្រហ្មទណ្ឌក៏ត្រូវតែទទួលបានដំណឹងអំពីសិទ្ធិនេះឱ្យបានគ្រប់គ្រាន់ជាមុនសិន មុននឹងផ្តល់ឱ្យពួកគេនូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីដោយខ្លួនឯង ឬដោយមានជំនួយពីមេធាវី។



ជនជាប់ចោទមានសិទ្ធិក្នុងការទទួលបានជំនួយពីមេធាវី ប្រសិនបើពួកគេមិនចង់ការពារក្តីដោយខ្លួនឯង។



សិទ្ធិនេះ អនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ ចាប់ពីដំណាក់កាល ស៊ើបអង្កេតបឋម រហូតដល់ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងឧទ្ធរណ៍។

ជនជាប់ចោទមានសិទ្ធិជ្រើសរើសមេធាវីការពារក្តីតំណាងឱ្យខ្លួនបាន។ ចំណុចនេះពិតជាមានសារសំខាន់ណាស់ដើម្បីធានាបានការទុកចិត្ត និងការជឿជាក់រវាងជនជាប់ចោទ និងមេធាវី និងនាំឱ្យមានការការពារក្តីប្រកបដោយប្រសិទ្ធិភាព។

ប្រសិនបើជនមិនអាចមានលទ្ធភាពជួលមេធាវីបាន ជនជាប់ចោទមានសិទ្ធិស្នើសុំមេធាវីដោយមិនគិតថ្លៃនៅពេលណាដែលផលប្រយោជន៍នៃយុត្តិធម៌ទាមទារ។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ

សិទ្ធិមានមេធាវីត្រូវបានការពារយ៉ាងច្បាស់ក្នុងមាត្រា ១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាន៖ ការជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។"



# ច្បាប់ជាតិ

សិទ្ធិមានមេធាវីត្រូវបានការពារដោយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា “ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។” សិទ្ធិនេះក៏បានចែងក្នុងមាត្រាមួយចំនួនដូចជា មាត្រា ១៤៣ មាត្រា ៣០០ និងមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមាត្រា ៦ និង ៥០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនផងដែរ។




## សារសំខាន់

ទោះបីជាដោយផ្ទាល់ ឬតាមរយៈមេធាវី សិទ្ធិការពារក្តីដោយខ្លួនឯង គឺមានសារសំខាន់ណាស់ក្នុងការធានាការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជនជាប់ចោទដែលត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌត្រូវតែទទួលបានការអនុញ្ញាតឱ្យតទល់នឹងការចោទប្រកាន់ប្រឆាំងនឹងខ្លួន។ សិទ្ធិមានមេធាវីគឺសសរស្តម្ភមួយ ដែលប្រកាន់ខ្ជាប់នូវសិទ្ធិស្មើគ្នារវាងភាគីជនជាប់ចោទ និងអយ្យការ ដែលជាគោលការណ៍សំខាន់នៃការជំនុំជម្រះដោយយុត្តិធម៌។





ការមានមេធាវីតំណាងជួយឱ្យជនជាប់ចោទរៀបចំការពារក្តីបានល្អប្រសើរ និងមានប្រសិទ្ធិភាពបំផុតដោយមានជំនួយពីបុគ្គលដែលមានជំនាញផ្នែកច្បាប់គ្រប់គ្រាន់ ដែលមានលទ្ធភាពពន្យល់បានគ្រប់គ្រាន់អំពីខ្លឹមច្បាប់នៃការចោទប្រកាន់ និងដើម្បីការពារផលប្រយោជន៍ជនជាប់ចោទនៅក្នុងតុលាការ ក៏ដូចជាធានាថាជនជាប់ចោទទាំងអស់ មានលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់ស្មើគ្នា ហើយជំនួយផ្នែកច្បាប់នោះគឺផ្តល់ជូនដោយមិនមានការរើសអើងនោះទេ។

## ដែនកំណត់



សិទ្ធិមានមេធាវីអាចត្រូវបានលះបង់ ប្រសិនបើជនជាប់ចោទមានបំណងការពារក្តីដោយខ្លួនឯង។ ប៉ុន្តែលះបង់សិទ្ធិនេះត្រូវតែធ្វើឡើងដោយមានសមត្ថភាពគ្រប់គ្រាន់ និងច្បាស់លាស់។ ជនជាប់ចោទក៏ត្រូវមានសិទ្ធិលុបចោលការលះបង់សិទ្ធិរបស់ខ្លួននៅអំឡុងពេលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌបានផងដែរ ប្រសិន បើ ពួកគេផ្លាស់ប្តូរចិត្ត។

លើសពីនេះ សិទ្ធិការពារក្តីដោយខ្លួនឯង គឺមិនមែនជាសិទ្ធិដាច់ខាតនោះទេ។ ជនជាប់ចោទអាចត្រូវបានចាត់តាំងមេធាវីឱ្យ ដែលខុសនឹងបំណងរបស់ខ្លួន នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវ។ ជារួមការរឹតត្បិតណាមួយទៅលើសិទ្ធិការពារក្តីដោយខ្លួនឯងត្រូវតែមានកត្តាសន្យានុម័ត និងគោលបំណងម៉ឹងម៉ាត់គ្រប់គ្រាន់ និងមិនឱ្យហួសពីអ្វីដែលចាំបាច់ ដើម្បីរក្សាផលប្រយោជន៍យុត្តិធម៌ឡើយ។





ទោះបីជាសិទ្ធិនេះមានសារសំខាន់ចំពោះជនជាប់ចោទក្នុងការជ្រើសរើសមេធាវីដែលខ្លួនឯងទុកចិត្ត ដើម្បីតំណាងយ៉ាងណាក្តី សិទ្ធិក្នុងការជ្រើសរើសនេះ ក៏មិនមែនជាសិទ្ធិដាច់ខាតដែរ និងអាចត្រូវបានរឹតត្បិតដោយហេតុផលសមស្រប និងសន្យានុម័ត ជាពិសេសប្រសិនបើរដ្ឋជាអ្នកបង់ថ្លៃសេវាមេធាវីនោះតែម្តង។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
Sweden Sverige
People Change the World Diakonia

CC BY NC SA